មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
គោលការណ៍ស្តីពី
មេរោគអេដស៍ / ជំងឺអេដស៍

កែសម្រួល៖ ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០

គោលការណ៍ស្តីពី
មេរោគអេដស៍ / ជំងឺអេដស៍

១. សេចក្តីផ្តើម

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») ទទួលស្គាល់ទំហំ និងភាពធ្ងន់ធ្ងរនៃមេរោគអេដស៍ / ជំងឺអេដស៍នៅទូទាំងពិភពលោក ក៏ដូចជានៅកម្ពុជាផងដែរ និងគាំទ្រដល់កិច្ចប្រឹងប្រែងនៅថ្នាក់ជាតិនិងអន្តរជាតិក្នុងការកាត់បន្ថយ និងលុបបំបាត់ការចម្លង និងបង្កើនការយល់ដឹង ការធ្វើតេស្ត និងការព្យាបាល។ ម.ស.ម.ក ហាមប្រាមការរើសអើងផ្អែកលើហេតុផលនៃមេរោគអេដស៍/ជំងឺអេដស៍ ហើយប្តេជ្ញាក្នុងការអនុវត្តវិធានការនៅកន្លែងការងារដើម្បីទប់ស្កាត់ការរើសអើងនេះ។ ម.ស.ម.ក ក៏ប្តេជ្ញាក្នុងការលើកម្ពស់ការយល់ដឹងអំពីមេរោគអេដស៍/ជំងឺអេដស៍ក្នុងចំណោមបុគ្គលិក និងអ្នកទទួលផលដើម្បីជួយបុគ្គលឱ្យជៀសផុតពីការឆ្លងផងដែរ។ វិធានការទាំងនេះមានចែងនៅក្នុងគោលការណ៍ស្តីពីមេរោគអេដស៍/ជំងឺអេដស៍នេះ (តទៅហៅថា «គោលការណ៍») ។

២. ការមិនរើសអើង

២.១. បទប្បញ្ញត្តិទូទៅទាក់ទងនឹងការមិនរើសអើង

អនុលោមតាមបទប្បញ្ញត្តិទាក់ទងនឹងការមិនរើសអើងនៅក្នុងគោលការណ៍ស្តីពីការងារ គោលការណ៍សមភាព និងគោលការណ៍យេនឌ័រ របស់ ម.ស.ម.ក ដែលជាគោលការណ៍ផ្តល់បរិយាកាសការងារមានលក្ខណៈសើរ គ្មានការរើសអើងលើបុគ្គលិករបស់ខ្លួន។

២.២. ការមិនរើសអើងផ្អែកលើហេតុផលនៃមេរោគអេដស៍/ជំងឺអេដស៍

ក) ម.ស.ម.ក មិនអនុគ្រោះចំពោះការរើសអើងលើបុគ្គលិក បេក្ខជន អ្នកម៉ៅការ ឬអ្នកទទួលផលដែលមានផ្ទុក ឬបញ្ជាក់ថាមានផ្ទុក ឬក៏រងប៉ះពាល់ដោយមេរោគអេដស៍/ជំងឺអេដស៍ឡើយ។

ខ) ម.ស.ម.ក ចាត់ទុកមេរោគអេដស៍/ជំងឺអេដស៍ ដូចគ្នានឹងជំងឺផ្សេងៗដែរ ពោលគឺមានការផ្តល់អត្ថប្រយោជន៍ដល់បុគ្គលិកតាមគោលការណ៍របស់យើង ក្នុងនោះរួមទាំង ច្បាប់ឈប់សម្រាកអនុលោមតាមគោលការណ៍ស្តីពីការងាររបស់ ម.ស.ម.ក។

គ) បុគ្គលិកដែលបដិសេធធ្វើការជាមួយ មិនផ្តល់សេវា ធ្វើការយោយី ឬ រើសអើងបុគ្គលិក ឬ អ្នកទទួលផលរបស់ ម.ស.ម.ក ដោយសារតែពួកគេមានផ្ទុក ឬបញ្ជាក់ថាមានផ្ទុក ឬ រងផលប៉ះពាល់ដោយមេរោគអេដស៍/ជំងឺអេដស៍ នឹងត្រូវប្រឈមវិធានពិន័យ ដែលអាចឈានដល់ការបញ្ឈប់ពីការងារអនុលោមតាមគោលការណ៍ស្តីពីការងាររបស់ ម.ស.ម.ក ។

ឃ) បុគ្គលិកដែលយល់ឃើញថាខ្លួនទទួលរងការរើសអើងដោយសារមានផ្ទុក ឬបញ្ជាក់ថាមានផ្ទុក ឬកំពុងរងផលប៉ះពាល់ពីមេរោគអេដស៍/ជំងឺអេដស៍ និងបុគ្គលិកទាំងឡាយដែលមានកង្វល់ពាក់ព័ន្ធផ្សេង

ទៀត ត្រូវបានលើកទឹកចិត្តឱ្យជជែកជាមួយអ្នកគ្រប់គ្រងផ្ទាល់របស់ខ្លួន ឬក៏សមាជិកគណៈកម្មាធិការគ្រប់គ្រងណាម្នាក់ដែលខ្លួនទុកចិត្ត និងយោងតាមនីតិវិធីបណ្តឹងតវ៉ា ដូចមានចែងក្នុងគោលការណ៍ស្តីពីការងាររបស់ ម.ស.ម.ក។ នីតិវិធីបណ្តឹងតវ៉ាគឺជាយន្តការផ្លូវការក្នុងការដាក់ពាក្យបណ្តឹងទាក់ទងនឹងការរើសអើង ហើយរាល់បណ្តឹងដែលទទួលបានតាមរយៈយន្តការនេះនឹងត្រូវបានដោះស្រាយយ៉ាងឆាប់រហ័ស និងមានទំនុកចិត្តពីគណៈកម្មាធិការគ្រប់គ្រង។

៣. ការធ្វើតេស្តរកមេរោគអេដស៍ និងការរក្សាការសម្ងាត់

៣.១. ការធ្វើតេស្តដោយស្ម័គ្រចិត្ត

ម.ស.ម.ក លើកទឹកចិត្តឱ្យមានការធ្វើតេស្តរកមេរោគអេដស៍/ជំងឺអេដស៍តាមគោលការណ៍ស្ម័គ្រចិត្ត និងការសម្ងាត់ ក្នុងចំណោមបុគ្គលិក និងអ្នកទទួលផល។ ម.ស.ម.ក ក៏លើកទឹកចិត្តដល់ការប្រឹក្សាយោបល់ជាសម្ងាត់សម្រាប់អ្នករស់នៅជាមួយមេរោគអេដស៍/ជំងឺអេដស៍ផងដែរ។ ម.ស.ម.ក មិនតម្រូវឱ្យបុគ្គលិក សមាជិកគ្រួសារក្នុងបន្ទុករបស់ពួកគេ បេក្ខជនដាក់ពាក្យស្នើសុំការងារ អ្នកទទួលផល ឬ បុគ្គលផ្សេងទៀតឆ្លងកាត់ការធ្វើតេស្តរកមេរោគអេដស៍ដើម្បីជាថ្នូរនឹងលក្ខខណ្ឌការងារ ការទទួលបានអត្ថប្រយោជន៍ ឬការទទួលបានសេវាកម្មរបស់ ម.ស.ម.ក ឡើយ។

៣.២. ការសម្ងាត់

មេរោគអេដស៍ / ជំងឺអេដស៍ ព្រមទាំងលក្ខខណ្ឌនៃការព្យាបាលផ្នែកវេជ្ជសាស្ត្រទាំងអស់ត្រូវបានរក្សាការសម្ងាត់។ ប្រសិនបើបុគ្គលិក បេក្ខជនដាក់ពាក្យស្នើសុំការងារ ឬ អ្នកទទួលផលបង្ហាញព័ត៌មានដល់ ម.ស.ម.ក ថាខ្លួនមានផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ នោះព័ត៌មាននេះនឹងត្រូវបានរក្សាការសម្ងាត់ទាំងស្រុង។ ការប្រើប្រាស់ព័ត៌មានសម្ងាត់ដោយមិនសមរម្យ គឺត្រូវប្រឈមនឹងវិធានពិន័យ ដែលអាចឈានដល់ការបញ្ឈប់ពីការងារអនុលោមតាមគោលការណ៍ស្តីពីការងាររបស់ ម.ស.ម.ក ។

៤. ការអប់រំ និងការយល់ដឹង

ម.ស.ម.ក មានការព្រួយបារម្ភអំពីសុខភាព និងសុវត្ថិភាពរបស់បុគ្គលិក និងក្រុមគ្រួសាររបស់ពួកគេ ព្រមទាំងអ្នកទទួលផលផងដែរ។ ម.ស.ម.ក នឹងផ្តល់ជូនដោយផ្ទាល់ ឬតាមរយៈតតិយជននូវឯកសារនានានិងការបណ្តុះបណ្តាលដើម្បីលើកកម្ពស់ការយល់ដឹង ដោយផ្តោតទៅលើមេរោគអេដស៍ / ជំងឺអេដស៍ និងវិធីបង្ការ។ បុគ្គលិក និងអ្នកទទួលផលដែលមានបំណងចង់ទទួលបានព័ត៌មានអំពីមេរោគអេដស៍ / ជំងឺអេដស៍ សូមអញ្ជើញចូលទៅអានឯកសារអប់រំនានារបស់ភ្នាក់ងារអប់រំជំងឺអេដស៍នៃអង្គការសហប្រជាជាតិ និងអង្គការសុខភាពពិភពលោកនៅលើបណ្តាញអ៊ីនធឺណិត ។ សំណើសុំព័ត៌មានបន្ថែមអំពីមេរោគអេដស៍ / ជំងឺអេដស៍ ដាក់ជូនទៅគណៈកម្មាធិការគ្រប់គ្រងនឹងត្រូវបានរក្សាការសម្ងាត់។